ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


២៦-០១-២០០៩ -ព្រះរាជក្រម នស/រកម/០១០៩/០០១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន មីសែល ខបភើរេសិន ៦០៩


### ២. ព្រះរាជក្រឹត្យ


២៤-៩-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៤ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៦២៥

០៤-១០-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១០០៨/១០៨៣ ស្តីពីការបញ្ចប់តំណែងទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការតែងតាំងមុនថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ និង ត្រូវបានតែងតាំងទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១០៤ រូប ៦២៦

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ដោនស្តាន ភីធើដូដ** (DUNSTAN PETER DODD) ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី កើតនៅក្រុងវ៉ូមេរ៉ា ប្រទេសអូស្ត្រាលី ៦៣០

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ៊ូ ស៊ីឡុង** (HU XI LONG) ជនជាតិចិន សញ្ជាតិចិន កើតនៅក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ៦៣១

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២៤ ស្តីពីការតែងតាំងឯកឧត្តម **ប៊ុណ្ណ ពិសិដ្ឋ** ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់នីតិកាលទី២ មានឋានៈស្មើអនុរដ្ឋលេខាធិការ ៦៣២

១៣-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ឆន ណាយ៉ុង** (CHON NA YONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុង ព្យុងយ៉ាង សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ ដោយប្តូរឈ្មោះជា **ឆន ណាវី**(CHON NAVY) ៦៣៣

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤១ ស្តីពីការតែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភាសម្រាប់នីតិកាលទី២ មានឋានៈស្មើអនុរដ្ឋលេខាធិការ ចំនួន ០៣ រូប ៦៣៤

២២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦២ ស្តីពីការតែងតាំងជាទីប្រឹក្សា និងជំនួយការរបស់ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី៤ ចំនួន ០៩ រូប ៦៣៥

២៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៣ ស្តីពីការតែងតាំងឯកឧត្តម **សំ ប្រជាមានិត** ជាជំនួយការឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៣៧

២៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៤ ស្តីពីការតែងតាំងឯកឧត្តម និងលោកជំទាវចំនួន ០២ រូបជានាយកខុទ្ទកាល័យ ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ២ រដ្ឋសភា ៦៣៨

២៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៦ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោកជំទាវ **ទេព បុប្ផាប្រសិទ្ធ** និង ឯកឧត្តមឧត្តមសេនីយ៍ទោ **យឿង សុខុន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៦៣៩

២៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៧ ស្តីពីការតែងតាំងឯកឧត្តម **សុខ ចំរើន** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ៦៤០

២៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៨ ស្តីពីការតែងតាំងឯកឧត្តម **រិន ទីរះ** ជាទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៤១

២៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រីនាយអាវុធហត្ថ នៃកងយោធពលខេមរភូមិន្ទចំនួន ០២ រូប ៦៤២

២៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៧០ ស្តីពីការតែងតាំងមុខងារជូនឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ុន ដែន** ជាអនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ ៦៤៣

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

៣០-០១-២០០៩ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា ៦ មាត្រា ៩ និងមាត្រា ១២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា ៦៤៤

៣០-០១-២០០៩ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិ សភាពាណិជ្ជកម្មកម្ពុជា ៦៤៧
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥០
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥១
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥២
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៥៤
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១១៩ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦៥៥
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៦
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៧
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៨
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៩
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៦០
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៦១
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៦២
៣០-០១-២០០៩ -អនុក្រឹត្យលេខ ១២៧ អនក្រ.តត ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ៦៦៥
០២-០២-២០០៩ -អនុក្រឹត្យលេខ ១២៨ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៦៦៦
០២-០២-២០០៩ -អនុក្រឹត្យលេខ ១២៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ៦៦៧
០២-០២-២០០៩ -អនុក្រឹត្យលេខ ១៣០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៦៨

## ២-សេចក្តីសំរេច

០២-០២-២០០៩ -សេចក្តីសំរេចលេខ ០៩ សសរ ស្តីពីការបង្កើតក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៦៧០

## III-ភារៈខារបណ្តាក្រសួខ

## ១-ធនាគារជាតិ នៃ កម្ពុជា

២០-០១-២០០៩ -ប្រកាសលេខ ធ៧.០៩.០១២ប្រក ស្តីពីសោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ៦៧២

២០-០១-២០០៩ -ប្រកាសលេខ ធ៧.០៩.០១៣ប្រក ស្តីពីការផ្តល់ឥណទានវិបារូបនី ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ៦៧៦

២៦-០១-២០០៩ -ប្រកាសលេខ ធ៧.០៩.០២០ប្រក ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ៦៩៥


## ២_លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៥៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **សាខាក្រុមហ៊ុន " សេរ៉ូល ថែល អេនជីនារីង "** ៦៩៩

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៦០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ប៊ី អោយ (ខេមបូឌា) ភីអិលស៊ី** ៧០០

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៦១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កំពង់ស្ពឺ ហ្វ្រីន អេហ្វ្រិខលឈរ៉ះ ឌីវេឡុបមេន ខូ អិលធីឌី** ៧០២

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៦២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ភី អេស (ខេមបូឌា)** ៧០៤

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៦៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផ្គុំស្រួច ញ៉ូហ្វុប** ៧០៦

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៦៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីត្រា ប៊ី អិម ជី (ខេមបូឌា) ប្រាយវេត លីមីធីត** ៧០៨

២២-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៧០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.អេច.ជី** ៧១០

# ព្រះរាជក្រម

នស/រកម/០១០៩/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនមីសែល ខបភើរេសិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ១ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រម
# លើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃ
# ព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនមីសែល ខបភើរេសិន

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុនមីសែល ខបភើរេសិន ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនមីសែល ខបភើរេសិន និងកិច្ចព្រមព្រៀងទិញថាមពលរវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុនមីសែល ខបភើរេសិន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ។ ការធានានេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតផានាទូទាត់នេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៖៧.០៩០១.០៦៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៦៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ មករា ឆ្នាំ២០០៩

**អគ្គលេខាធិការគណៈរដ្ឋមន្ត្រី/រាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ៥៥ ស.ប្រ.ក

## សិទ្ធិប្រទាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសម្បទាន

-បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង IMPLEMENTATION AGREEMENT (IA) លើកិច្ចព្រមព្រៀងជួល LEASE AGREEMENT (LA) និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា GOVERNMENT GUARANTEE OF PAYMENT ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅឱ្យក្រុមហ៊ុន MICHELLE CORPORATION សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីស្ទឹងឬស្សីជ្រុំក្រោម កម្លាំង ៣៣៨ មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* MINISTRY OF ECONOMY AND FINANCE *

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៤......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៨

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ : **លោក** LEE HANKHEANG

**ក្រុមហ៊ុន** MICHELLE CORPORATION

អាស័យដ្ឋាន: ផ្ទះលេខ 17, ផ្លូវលេខ 55, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ : 855 23 866 666

**យោង :**

(ក) សិទ្ធិប្រទាន លេខ ៥៥ សប្រទ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (លិខិតសិទ្ធិប្រទាន ក្នុងឧបសម្ព័ន្ធ១) ។

(ខ) **កិច្ចព្រមព្រៀងអនុវត្តគម្រោង** (IA) ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** «**ឧ រ ថ**» និងក្រុមហ៊ុន MICHELLE CORPORATION «**ក្រុមហ៊ុន**» ។

(គ) **អគ្គិសនីកម្ពុជា «អកក»** ជាសហគ្រាសរដ្ឋ ដែលមានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/កក/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ **«អកក»** ដែលបានចុះកិច្ចព្រមព្រៀងទិញលក់អគ្គិសនី (PPA) ជាមួយ **«ក្រុមហ៊ុន»** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ ។

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** យល់ព្រមផ្តល់: (១)-ការធានាការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែលអគ្គិសនីកម្ពុជាមិនធ្វើការទូទាត់ និង (២)-ការធានាទិញមធ្យោបាយគម្រោងដោយបញ្ចប់កិច្ចព្រមព្រៀងស្របតាម **កិច្ចព្រមព្រៀងទិញលក់អគ្គិសនី** និង/ឬ **កិច្ចព្រមព្រៀងអនុវត្តគម្រោង** ក្នុងករណីដែល **«ក្រុមហ៊ុន»** មិនអាចដំណើរការអាជីវកម្មបាន ដោយកើតចេញពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ ។

(ង) តាមការតម្រូវក្នុងផ្នែក៩.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ «ក្រ ស ហ វ»** ជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា **«អ្នកធានា»** បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាទូទាត់របស់ **«អគ»/«ក្រ ឧ រ៉ ថ»** ស្របតាម **កិច្ចព្រមព្រៀងទិញលក់អគ្គិសនី** និង **កិច្ចព្រមព្រៀងអនុវត្តគម្រោង** ។

**ដូច្នេះយើងខ្ញុំសូមធានា ថា:**

១. **អ្នកធានា** ធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យ **«ក្រុមហ៊ុន»** នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ដែលត្រូវបង់ និងជំពាក់ដោយ **«អគ»/«ក្រ ឧ រ៉ ថ»** ឱ្យ **«ក្រុមហ៊ុន»** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ដែល**«អគ»/«ក្រ ឧ រ៉ ថ»** ខកខានពុំបានទូទាត់ អនុលោមតាមលក្ខខណ្ឌ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ។

២. លិខិតធានានេះ ត្រូវជាការធានាថា បន្តរហូត និង ឱ្យបានសមស្រប និង ត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យ **«ក្រុមហ៊ុន»** គ្រប់ពេលដោយ **«ក្រ ឧ រ៉ ថ»** ឬ **«អគ»** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយ ពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង **«ក្រ ឧ រ៉ ថ»** ឬ **«អគ»** ឬ ក្នុងនាម ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់អនុវត្តលិខិតធានានេះ និងតម្រូវការទូទាត់ពីអ្នកធានា **«ក្រុមហ៊ុន»** ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ សម្រាប់ការទូទាត់ពី **«ក្រ ឧ រ៉ ថ»**ឬ **«អគ»** ។ ក្រោយទទួលវិក្កយប័ត្រ ហុកសិប (៦០) ថ្ងៃ ដូចមានចែងក្នុងផ្នែក៨.៧.១ នៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬសំណើទូទាត់ណាមួយពី **«ក្រុមហ៊ុន»**ទៅ **«ក្រ ឧ រ៉ ថ»** ឬ **«អគ»** **«ក្រុមហ៊ុន»** អាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ **«ក្រ ឧ រ៉ ថ»**ឬ **«អគ»**បានហួសកាលកំណត់ និងលើកសំណើទូទាត់ពី អ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់ របស់អ្នកធានា ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូកបីភាគរយ (៣%) ។ ហើយពុំមានសំណើណា ដែលធ្វើឡើងដោយ**«ក្រុមហ៊ុន»** ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់**«ក្រុមហ៊ុន»** ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រមិនបានទូទាត់ផ្សេងទៀត ។

ទឹកប្រាក់ទាំងអស់ដែលអ្នកធានា ត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល**«ក្រុមហ៊ុន»** បានកំណត់ ជាដុល្លារអាមេរិកឱ្យ**«ក្រុមហ៊ុន»** ។

៤. រាល់ការធ្វើសំណើទូទាត់ណាមួយ ដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬតាមរយៈបុគ្គល ដែលជាមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់ របស់**«ក្រុមហ៊ុន»**នៅការិយាល័យរបស់អ្នកធានា និង

ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់ របស់ **«ក្រុមហ៊ុន»** ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា :

យើងខ្ញុំសូមបញ្ជាក់ថា :

(១) **ក្រុមហ៊ុន** MICHELLE CORPORATION **«ក្រុមហ៊ុន»** បានធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ **«អ្នកធានា»** ក្នុងចំនួនទឹកប្រាក់.................. {បញ្ចូលទឹកប្រាក់} ជាដុល្លារអាមេរិក ស្របតាមផ្នែក១ នៃលិខិតធានា របស់រាជរដ្ឋាភិបាល លើការទូទាត់ ចុះថ្ងៃទី ...... ខែ ....... ឆ្នាំ ២០០៨ រវាង **«អ្នកធានា»** និង **«ក្រុមហ៊ុន»** ។

(២) ចំនួនទឹកប្រាក់កំណត់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ **«ក្រ ខ្ញ រ៍ ៩»** ឬ **«អគ»** ស្របតាម កិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាង **«ក្រុមហ៊ុន»** និង **«ក្រ ខ្ញ រ៍ ៩»** ឬ **«អគ»** និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃជម្លោះ រវាង **«ក្រ ខ្ញ រ៍ ៩»**/ **«អគ»** និង **«ក្រុមហ៊ុន»** ។

(៣) សំណើទូទាត់ពី **«ក្រ ខ្ញ រ៍ ៩»**/ **«អគ»** ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ ។

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ **«ក្រ ខ្ញ រ៍ ៩»**/ **«អគ»** រហូតដល់ថ្ងៃនេះ ។

៥. **អ្នកធានា** សូមអះអាង និងធានានៅថ្ងៃនេះថា :

- អ្នកធានាមានសិទ្ធិអំណាច និងការអនុញ្ញាតស្របច្បាប់ ដើម្បីអនុវត្ត និងប្រគល់ ព្រមទាំងប្រតិបត្តិតាម លក្ខខណ្ឌ នៃលិខិតធានានេះ ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណង ដែលអ្នកធានា ត្រូវអនុវត្តអនុលោមតាមលក្ខខណ្ឌរបស់វា ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការអនុវត្ត ត្រូវបានទទួលក្រោមច្បាប់ នៃព្រះរាជាណាចក្រ កម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការអនុវត្ត ការផ្គត់ផ្គង់ និងការប្រតិបត្តិលិខិតធានានេះ ។
- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានា របស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌ របស់អ្នកធានា ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សម្រាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ។
- អ្នកធានាបានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការអនុវត្ត និងការផ្តល់ជូន ដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពជាសាធារណៈ ឬជា សកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាច បដិសេធបានឡើយ ។

- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់គេ ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ មិនមានអភ័យឯកសិទ្ធិណា ពីបណ្តឹងត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់គេ ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត ។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីថ្ងៃចាប់ផ្តើមកាលបរិច្ឆេទការសាងសង់ (Construction Commencement Date) រហូតដល់បញ្ចប់អាណត្តិ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី និងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល«**ក្រុ ខ្ញុំ ៩**» ឬ «**អគក**» ជំពាក់ «**ក្រុមហ៊ុន**» ទាក់ទងនឹងលក្ខខណ្ឌ ឬនៅពុំទាន់សង ។ ប៉ុន្តែទោះបីយ៉ាងណា ក្នុងករណីនៃការធានាទិញថាមពល ក្នុងករណីដែលអគ្គិសនីកម្ពុជាពុំបានទូទាត់ថ្លៃថាមពល លិខិតធានានេះ ត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគម្រោង (Commercial Operation Date) ដូចមាននិយមន័យ កំណត់នៅក្នុងកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយ ដោយ«**ក្រុមហ៊ុន**» ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមការធានានេះ ជាការបដិសេធ ឬការដោះស្រាយឡើយ ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬមួយផ្នែក ដោយភាគីណាមួយ ប្រានចោលការអនុវត្តបន្ថែមផ្សេងទៀត ឬការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀត ។ ការបដិសេធរបស់ «**ក្រុមហ៊ុន**» មានប្រសិទ្ធភាព លុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យ«**ក្រុមហ៊ុន**» ដោយការធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលបន្ទាប់ពីនេះទៅ ត្រូវហៅរួមគ្នាថា «**លិខិតជូនដំណឹង**») ដែលត្រូវផ្តល់ ឬធ្វើឡើង ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល ដូចខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍ ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់:

(ក) ពេលប្រគល់ផ្ទាល់ដៃ ឬ

(ខ) នៅពេលប្រគល់មានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់បញ្ជូនទៅភាគីដែលបានទទួល ទៅអាសយដ្ឋាន ដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដូចជាភាគីនោះ អាចកំណត់ដោយលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម):

សម្រាប់ **អ្នកធានា:**

| | |
|---|---|
| ជូនចំពោះ | : **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** |
| អាសយដ្ឋាន | : ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | : ៨៥៥-២៣ ៤២៧ ៧៩៨ |

សម្រាប់ «**ក្រុមហ៊ុន**» :

ជូនចំពោះ : **លោក** LEE HANKHEANG
**ក្រុមហ៊ុន** MICHELLE CORPORATION
អាស័យដ្ឋាន : ផ្ទះលេខ 17, ផ្លូវលេខ 55, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារ : 855 23 866 666

ឬក៏អាសយដ្ឋានផ្សេងទៀត ដូចដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានា មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ជាមុនពី«**ក្រុមហ៊ុន**»ឡើយ ហើយ«**ក្រុមហ៊ុន**»មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះ សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍របស់គម្រោង «**ក្រុមហ៊ុន**»អាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានអត្ថប្រយោជន៍ដល់អ្នកធានា និង«**ក្រុមហ៊ុន**» ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និង«**ក្រុមហ៊ុន**» អនុលោមតាមលិខិតធានានេះ និងលក្ខខណ្ឌរបស់វា ត្រូវបានគ្រប់គ្រង និងបកស្រាយតាមច្បាប់ នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តវិនិច្ឆ័យផងដែរ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធទៅនឹងលិខិតធានានេះ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និង«**ក្រុមហ៊ុន**»ត្រូវសាកល្បងដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ គេត្រូវដាក់វិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងមាត្រានេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ មាត្រានេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និង«**ក្រុមហ៊ុន**» និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងនោះ ត្រូវអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ មិនអាចបដិសេធដោយឥតប្រកែកបាន នូវសិទ្ធិណាមួយដែលគេមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះមានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេច របស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានកំណត់ផ្សេងពីនេះដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការ

ប្រាក់តាមអត្រា LIBOR បូកបីភាគរយ (៣%) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យ នោះ ចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច ។

១២. ពាក្យសរសេរជាអក្សរធំដែលប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង កិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង តាមដែលអាចអនុវត្តបាន ។

១៣. ប្រសិនបើបញ្ញត្តិមួយឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ភាពខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិនោះពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិសេសសល់ផ្សេងទៀត នៃលិខិតធានានេះឡើយ ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់ ការប្តឹងទាមទារ ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះ«**ក្រុមហ៊ុន**» ត្រូវតែមានសម្រាប់អ្នកធានា ចំពោះ«**ក្រុមហ៊ុន**» ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកធានា ចំពោះ«**ក្រុមហ៊ុន**» ស្របតាមលិខិតធានានេះ ។

១៤. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពី «**ក្រុមហ៊ុន**» ជូនមកអ្នកធានា ត្រូវតែទទួលបានមុនពេលផុតកំណត់នោះ ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តទៅបាន បន្ទាប់ពីទទួលបានការអនុម័ត ពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោកមេត្តាទទួលនូវការស្រឡាញ់រាប់អាន ដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ជំនួសមុខ និង តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា**

គាត ឈន់

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-អគ្គិសនីកម្ពុជា
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

***Royal Government***

ជាតិ សាសនា ព្រះមហាក្សត្រ

***Nation Religion King***

N: 55 DFP

**Phnom Penh, June 19 , 2008**

# DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0704/124 dated 15 of July 2004 on the nomination of the Royal Government of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/1207/035 dated 21 of December 2007 promulgating the Law on Finance for Management of Fiscal Year 2008
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law of Concessions
- Seen Sub-decree 111 អនុក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Seen decision of Council of Ministers in its plenary session on 13 June 2008.

## The Royal Government

Delegates herewith to H.E. Mr. KEAT CHHON, Senior Minister, Minister of Economy and Finance, full power to sign the Implementation Agreement (IA), Lease Agreement (LA), and the Government Guarantee of Payment by the EDC to MICHELLE CORPORATION for the Development of Lower Russey Chrum Hydro-Electric BOT Project in Koh Kong Province.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**

28

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 004 MEF/

Phnom Penh, 23 JUNE ,2008

# GOVERNMENT GUARANTEE OF PAYMENT

| | |
|---|---|
| To | : MICHELLE CORPORATION |
| Address | : No. 17, Street 55, Sangkat Chaktomouk, Khan Daun Penh, Phnom Penh, Cambodia. |
| Fax No. | : 855 23 866 666 |
| Attention | : Mr. Lee Hankheang |

Dear Sir,

We refer to:

(A) Delegation of Full Power No. 55 DFP dated 19 June 2008 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. **(Please see attachment 1)**

(B) The Implementation Agreement ("IA") dated 20 June 2008, entered between the Royal Government of Cambodia ("RGC") represented by Minister of Ministry of Industry, Mines, and Energy ("MIME") and Michelle Corporation and any of its permitted successors in title and assignees (the "Company").

(C) ELECTRICITE DU CAMBODGE, a wholly state-owned limited enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Purchase Agreement ("PPA") with the Company dated 20 June 2008.

(D) The Royal Government of Cambodia agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with PPA and/or IA in the event that the "Company" is unable to operate the Project arising from the Force Majeure Political Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance ("MEF") on behalf of Royal Government of Cambodia (the "Guarantor") has agreed to issue into this Guarantee of the payment obligations of EDC/MIME under the PPA and the IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay the "Company" any and every sum of money which is due and owed by MIME or EDC to the "Company" under the IA or PPA that MIME or EDC has failed to pay in accordance with the terms of the IA or PPA.

2. This guarantee shall be a continuing security and accordingly, shall extend to cover the balance due to the "Company" at any time from MIME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the "Company" shall be obliged only to make demand in writing for payment from MIME or EDC. Any time after sixty (60) Days from the date of the invoice(s) as specified in Section 8.7.1. of the PPA or any payment demand from the "Company" to EDC or MIME being received by EDC or MIME, the "Company" may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) Days of such notice. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the "Company" hereunder shall prejudice or restrict the right of the "Company" to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the "Company" in the Kingdom of Cambodia in US Dollars to the "Company".

4. Any demand for payment made pursuant to this guarantee shall be made by courier or in person by a duly authorized officer of the "Company" at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the "Company" stating, without the obligation to substantiate, that:

   "We hereby certify that:
   (1) Michelle Corporation (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars----- [insert amount] in accordance with Section 1 of the Guarantee dated --------, between the Guarantor and the "Company";
   (2) The amount specified above is due and payable by [EDC or MIME] under the PPA/IA between the "Company" and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and the "Company";
   (3) Demand in writing for payment from MIME/EDC has been made;
   (4) Such amount, on the date hereof remains unpaid by MIME/EDC."

5. The Guarantor warrants that, as of the date hereof:
   - The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
   - This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.

- All necessary action has been taken, and all approvals required have obtained, under the Laws of Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against it or its assets in any jurisdiction in relation to this Grarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the Term of the IA or PPA and for so long thereafter as any amount owed to the "Company" by EDC in connection with such term is or may be outstanding. However, such Guarantee on power purchase in the event of non-payment by EDC for the Energy shall be applicable from the Commercial Operation Date (COD), as definition stipulated in the PPA of the Project.

7. No failure or delay by the "Company" to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the "Company" shall be effective unless it is in writing. The rights and remedies of the "Company" provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) when presented personally, or
   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

   For the Guarantor:
   Address : Ministry of Economy and Finance
   Facsimile : 855 23 427 798
   Attention : Minister, Ministry of Economy and Finance

   For the "Company" : MICHELLE CORPORATION
   Address : No. 17, Street 55, Sangkat Chaktomouk, Khan Daun Penh, Phnom Penh, Cambodia.
   Fax No. : 855 23 866 666
   Attention : Mr. LEE HANKHEANG

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the "Company", and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the "Company" may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the "Company" and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the "Company" under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the "Company" shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the "Company" and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement or IA, as applicable.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee. Subject to mutual agreement, no set-off counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the "Company" shall be available to the Guarantor against the "Company" in connection with any obligation of the Guarantor to the "Company" under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to the

Guarantor by the "Company" hereunder must therefore be received by the Guarantor before that time.

15. This Guarentee shall become in Full force and effect on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully,

Keat Chhon
Senior Minister
Minister of Economy and Finance
Acting on behalf of Royal Government of Cambodia

CC:

- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council of Ministers
- Ministry of Foreign Affairs and International Cooperations
- Ministry of Industry Mine and Energy
- Council for the Development of Cambodia (CDC)
- Cabinet of Semdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Electricite du Cambodge (EDC)
- File

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៨/១០៥៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៦០៤/០៨ គជប សសរ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨
- បានទ្រង់យល់សំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ៦៤៤ លគគក ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨
- បានទ្រង់យល់សំណើរបស់ព្រឹទ្ធសមាជិករដ្ឋសភានីតិកាលទី៤ លេខ ៧៧៣ រស ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានចាត់តាំង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចរៀបចំសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៩០៩.១០៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨

លេខ: ៩៩៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៨/១០៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១៖** ត្រូវបានបញ្ចប់តំណែងទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការតែងតាំងមុនថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ។

**មាត្រា ២៖** ត្រូវបានតែងតាំងទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | គន់ | គីម | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- | ឯកឧត្តម | ហូ | សិទ្ធី | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- | ឯកឧត្តម | ប្រាក់ | សុខុន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- | ឯកឧត្តម | ឱម | យ៉ិនទៀង | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥- | ឯកឧត្តម | មល់ | រឿប | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦- | ឯកឧត្តម | យូ | ស៊ុនឡុង | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៧- | ឯកឧត្តម | អូន | ព័ន្ធមុនីរ័ត្ន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៨- | ឯកឧត្តម | នុត | ឈឿម | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | |

| | | | | | |
|---|---|---|---|---|---|
| ៩- | ឯកឧត្តម | ឌុល | គឿន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១០- | ឯកឧត្តម | សុខ | ចិន្តា | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១១- | ឯកឧត្តម | ប៉ែន | ស៊ីម៉ន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១២- | ឯកឧត្តម | អិន | ឃន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៣- | ឯកឧត្តម | ឈៀង | យ៉ាណារ៉ា | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៤- | ឯកឧត្តម | ឃុន | ឈី | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | |
| ១៥- | ឯកឧត្តម | សុន | គន្ធរ | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៦- | ឯកឧត្តម | អ៊ុក | ចាន់ | មានឋានៈស្មើ រដ្ឋមន្ត្រី | |
| ១៧- | ឯកឧត្តម | គៀង | សារុធ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៨- | ឯកឧត្តម | សួន | សិទ្ធី | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៩- | ឯកឧត្តម | គង់ | វិបុល | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២០- | ឯកឧត្តម | ហ៊ីង | ប៊ុនហៀង | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២១- | ឯកឧត្តម | ហ៊ុយ | ពិសិដ្ឋ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២២- | ឯកឧត្តម | ស្រ៊ុំ | ថាមរុង្គ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៣- | ឯកឧត្តម | ម៉ម | សារិន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៤- | ឯកឧត្តម | ឈុន | ស៊ីរុន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៥- | ឯកឧត្តម | ស៊ូ | ភិរិន្ទ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៦- | ឯកឧត្តម | ជៀង | អំ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៧- | ឯកឧត្តម | ឡូយ | សុផាត | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៨- | ឯកឧត្តម | ណាំ | ទុំ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៩- | ឯកឧត្តម | ខាំ | ភឿន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣០- | ឯកឧត្តម | ទូច | ម៉ារីម | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣១- | ឯកឧត្តម | ស្រី | បេន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣២- | ឯកឧត្តម | យុទ្ធ | ភូថង | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៣- | ឯកឧត្តម | មួង | ប៉យ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៤- | ឯកឧត្តម | កង | ប៉ាង | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៥- | ឯកឧត្តម | កែប | ជុតិមា | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៦- | ឯកឧត្តម | អ៊ី | ឈាន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៧- | ឯកឧត្តម | ឆាយ | សារ៉េត | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៨- | ឯកឧត្តម | ព្រាប | គាន់ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៩- | ឯកឧត្តម | ប៊ិច | សុខិន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤០- | ឯកឧត្តម | ហាស់ | សារ៉េត | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤១- | ឯកឧត្តម | ឡាយ | សុខា | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤២- | ឯកឧត្តម | ប្រាជ្ញ | ច័ន្ទ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៣- | ឯកឧត្តម | ហ៊ុន | ណេង | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៤- | ឯកឧត្តម | អ៊ុង | សាមី | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៥- | ឯកឧត្តម | ស្បោង | សារ៉ាត | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

6/8

| | | | | | |
|---|---|---|---|---|---|
| ៤៦- | ឯកឧត្តម | ខូយ | ឃុនហ៊ួរ | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៧- | ឯកឧត្តម | អ៊ុង | អឿន | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៨- | ឯកឧត្តម | ចក់ | ឡេង | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤៩- | ឯកឧត្តម | ជា | តារា | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥០- | ឯកឧត្តម | អ៊ុយ | សុភាព | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥១- | ឯកឧត្តម | វង្សី | វិស្សុត | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥២- | ឯកឧត្តម | ពុង | ឃាវសែ | មានឋានៈស្មើ រដ្ឋមន្ត្រី | |
| ៥៣- | ឯកឧត្តម | ម៉ម | ប៊ុននាង | មានឋានៈស្មើ រដ្ឋមន្ត្រី | |
| ៥៤- | ឯកឧត្តម | ប៊ុន | សំបូរ | មានឋានៈស្មើ រដ្ឋមន្ត្រី | |
| ៥៥- | ឯកឧត្តម | ខ្វាន់ | ស៊ាម | មានឋានៈស្មើ រដ្ឋមន្ត្រី | បន្ថែមលើមុខងារបច្ចុប្បន្ន |
**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដូចមាននាមខាងក្រោម ÷

១- លោក **ហ៊ិន សុន**

២- លោក **កង ប៊ុន**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១ :** តែងតាំងលោក **គីម រិទ្ធី** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥ . អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនកងកំលាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ១៣រូប ដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ច និង ចូលរួមឧបត្ថម្ភ ដល់កងកំលាំងការពារបូរណភាពទឹកដីទិសប្រាសាទព្រះវិហារ ដូចមានរាយនាមខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | **រ៉េត ស៊ីថា** | ៨- | លោក | **អ៊ូ ធួក** |
| ២- | ឧត្តមសេនីយ៍ត្រី | **ឡោ តុងហាំង** | ៩- | លោក | **កៅ ឈុង** |
| ៣- | វរសេនីយ៍ទោ | **ឆា ប្រាំនណា** | ១០- | លោក | **វណ្ណ កុសល** |
| ៤- | វរសេនីយ៍ទោ | **លឹម សាឡង់ឌី** | ១១- | លោក | **គីម ស្រ៊ុនកុសល** |
| ៥- | វរសេនីយ៍ទោ | **អ៊ុច នី** | ១២- | លោក | **ឃុន ពៅ** |
| ៦- | វរសេនីយ៍ទោ | **អៀ សុផល** | ១៣- | លោក | **មួង ដារ៉ា** |
| ៧- | លោក | **សេង សារ៉េន** | | | |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៦-អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនកងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ ចំនួន ៦០ រូប ដែលមានស្នាដៃល្អឆ្នើម ក្នុងការបំពេញភារកិច្ចការពារបូរណភាពទឹកដីទិសប្រាសាទព្រះវិហារ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | អនុសេនីយ៍ឯក | **ហ៊ួត គីមស្រៀង** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ២- | អនុសេនីយ៍ឯក | **តាំង វណ្ណៈ** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៣- | អនុសេនីយ៍ឯក | **ម៉ាង សុផាត** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៤- | អនុសេនីយ៍ឯក | **ឡុង យ៉េម** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៥- | អនុសេនីយ៍ឯក | **យ៉ី ស៊ីម** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៦- | អនុសេនីយ៍ឯក | **ណាង ប៊ុនថេង** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៧- | អនុសេនីយ៍ឯក | **ខាំ និន** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៨- | អនុសេនីយ៍ឯក | **នួន ផល** | ការិយាល័យបច្ចេកទេស កងទ័ពជើងគោក |
| ៩- | អនុសេនីយ៍ឯក | **អ៊ុច សុឃឿន** | ក្រុមគ្រូពេទ្យចល័តអគ្គបញ្ជាការ |
| ១០- | អនុសេនីយ៍ឯក | **ហេង ចាន់ណា** | ក្រុមគ្រូពេទ្យចល័តអគ្គបញ្ជាការ |
| ១១- | អនុសេនីយ៍ឯក | **ម៉ៅ សេរីវុឌ្ឍី** | ក្រុមគ្រូពេទ្យចល័តអគ្គបញ្ជាការ |
| ១២- | អនុសេនីយ៍ឯក | **ឌុយ ប៊ុនធឿន** | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |

| | | |
|---|---|---|
| ១៣- អនុសេនីយ៍ឯក | សេក សំអាត | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ១៤- អនុសេនីយ៍ឯក | ព្រហ្ម សារឿន | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ១៥- អនុសេនីយ៍ឯក | ប្រាក់ ឧត្តម | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ១៦- អនុសេនីយ៍ឯក | ប៉ុច ឡឿន | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ១៧- អនុសេនីយ៍ឯក | ហ៊ី សុវណ្ណ | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតតេជោ ហ៊ុន សែន |
| ១៨- អនុសេនីយ៍ឯក | ខែម សុខា | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ១៩- អនុសេនីយ៍ឯក | ប្រាក់ ចិន្តា | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២០- អនុសេនីយ៍ឯក | សុទ្ធ ថា | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២១- អនុសេនីយ៍ឯក | សាន ណៃ | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២២- អនុសេនីយ៍ឯក | ឈិន វិបុល | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២៣- អនុសេនីយ៍ឯក | ញឹម សារិទ្ធ | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២៤- អនុសេនីយ៍ឯក | ជា សុធន | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២៥- អនុសេនីយ៍ឯក | ឈុប ហាក់ | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២៦- លោក | យុន ពៅ | |
| ២៧- លោក | មឿន ធីរត្ន | |
| ២៨- លោក | ស៊ុន នួយ | |
| ២៩- លោក | មួយ ម៉ុច | |
| ៣០- លោក | តី សៀន | |
| ៣១- អនុសេនីយ៍ទោ | ឆាន់ ញឿល | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣២- អនុសេនីយ៍ទោ | ឯម ស៊ីចាន់ | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៣- អនុសេនីយ៍ទោ | ហ៊ី ចិន្តា | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៤- អនុសេនីយ៍ទោ | គង់ សុធា | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៥- អនុសេនីយ៍ទោ | អ៊ុច ស៊ីនឿន | វរសេនាតូច១៧៩ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៦- អនុសេនីយ៍ទោ | គង់ ម៉ាញ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៧- អនុសេនីយ៍ទោ | ក្រិច ចក្រី | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៨- អនុសេនីយ៍ទោ | សៅ សុភា | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៣៩- អនុសេនីយ៍ទោ | កែវ វុឌ្ឍី | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤០- អនុសេនីយ៍ទោ | មិញ សាបឿន | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤១- អនុសេនីយ៍ទោ | សន សុឃុយ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤២- អនុសេនីយ៍ទោ | មិញ វីរៈ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៣- អនុសេនីយ៍ទោ | ផាន់ សុវ៉ាន់ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៤- អនុសេនីយ៍ទោ | ម៉ែន សារ៉ា | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៥- អនុសេនីយ៍ទោ | ជា វិចិត្រ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៦- អនុសេនីយ៍ទោ | សាន្ត សុគន្ធ | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតី តេជោហ៊ុន សែន |
| ៤៧- អនុសេនីយ៍ទោ | មួន រ័ត្ន | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៨- អនុសេនីយ៍ទោ | គីម សុភាព | វរសេនាតូច២៤៦ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៤៩- អនុសេនីយ៍ទោ | មិន សុផល | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |

| | | | |
|---|---|---|---|
| ៥០- | អនុសេនីយ៍ទោ | **ចាន់ សេរីបុត្រ** | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥១- | អនុសេនីយ៍ទោ | **ហ៊ួន ប៊ុនម៉ៅ** | វរសេនាតូចស៊ើបការណ៍ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥២- | ព្រិន្ទបាលឯក | **នៅ សុឃាន់** | វរសេនាតូចកងរាជអាវុធហត្ថកងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៣- | ព្រិន្ទបាលឯក | **អ៊ុំ សុភាព** | វរសេនាតូចកងរាជអាវុធហត្ថកងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៤- | ពលបាលឯក | **គៀន សារុន** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៥- | ពលបាលឯក | **សុខ ជា** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៦- | ពលបាលឯក | **ឈុន ចិត្រា** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៧- | ពលបាលឯក | **យ៉េយ សុះនី** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៨- | ពលបាលឯក | **សួន រ៉ា** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៥៩- | ពលបាលឯក | **ឡុង បូណា** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ៦០- | ពលបាលឯក | **លីវ ពន្លឺខេមរ៉ា** | វរសេនាតូច ១៦៧ កងឯកភាពអង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។
- ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣០៣ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៨

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបញ្ចប់ភារកិច្ចលោក **ឃួរ សំអើល** ប្រធាននាយកដ្ឋានអភិរក្ស នៃក្រសួងព្រះបរមរាជវាំង ដោយចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ។

**មាត្រា ៣ :** អនុក្រឹត្យនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..១៤៧..អនក្រ.តត

## អនុក្រឹត្យ

ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការបង្កើតខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមុខតំណែងលោក **ឃួន ស្រេង** បាននូរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ ជាអភិបាលខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០៩

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៩ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ខេង សុមេធ** អត្តលេខ ០៧២៧១ ពីស្នងការរង និងជាប្រធានការិយាល័យប្រឆាំងបទល្មើស នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣០ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់សម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជា ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

## សម្រេច

**មាត្រា ១ :** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៣៥រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមបំពេញភារកិច្ច រៀបចំពិធីបុណ្យខួបលើកទី៣០ នៃទិវាជ័យជំនះ ៧មករា ឆ្នាំ ២០០៩ ដូចមានរាយនាមខាងក្រោម :

**ក- មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | ប៊ុច ម៉េងហេង | ២-លោក | ញ៉ែម សុខជា |
| ៣-លោក | យស់ សក្តិដា | ៤-លោក | យួន ចាន់សុខ |
| ៥-លោក | លន់ សូផាន | ៦-លោក | ពេជ ម៉ាន |
| ៧-លោក | ខៀម សារុន | ៨-លោក | តែ សុខរិទ្ធ |
| ៩-លោក | ថាន់ ពៅ | ១០- លោក | សៅ ម៉ាន់ដេត |
| ១១-លោក | ឆុង ឈឿន | ១២-លោក | ថូ សុគន្ធី |

| | |
|---|---|
| ១៣-លោកស្រី អៀង សុនគ្រា | ១៤-លោកស្រី អ៊ុម ណារិន |
| ១៥-លោក ឈឿន រិទ្ធ | ១៦-លោក ឆេង សារិន |
| ១៧-លោក ជ័យ គីរីរ៉េម | ១៨-លោកស្រី ថោង សុខា |
| ១៩-លោក ទូត យ៉ាត | |

ខ- មេដាយប្រាក់ការងារ :

| | |
|---|---|
| ១-លោក ចាន់ សំអឿន | ២-លោក ឈឹម ប៊ុនណា |
| ៣-លោក សេក ហឿង | ៤-លោក សៀង ប៊ុនហេង |
| ៥-លោក ឡាយ សេង | ៦-លោក តែង អាន |
| ៧-លោក ផាត់ ហ៊ិន | ៨-លោក ឈួន សុង |
| ៩-លោក ថូ សំអាត | ១០-លោកស្រី ស៊ិន ចាសនា |
| ១១-លោកស្រី អ៊ុន ស៊ីណុន | ១២-លោកស្រី ចាន់ ថាវី |
| ១៣-លោកស្រី ម៉ា ម៉ូលី | ១៤-លោកស្រី សេង រ៉ាមីន |
| ១៥-លោកស្រី តែង ចណ្ណរីម | ១៦-លោក ហែម សុគន្ធ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០៩ ស.សរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើតក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អ៊ុយ ស៊ីម** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** | ប្រធាន |
| ២- ឯកឧត្តម | **ខៀវ សុភ័គ** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

៣- ឯកឧត្តម **ឈើច មង្គល** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** លេខាធិការ

**ប្រការ ២.-** ភារកិច្ចរបស់ក្រុមគ្រប់គ្រងទីប្រឹក្សា ជំនួយការ :

- ពាំនាំនូវបញ្ហា និងសេចក្តីណែនាំនានារបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូនឯកឧត្តម លោកជំទាវ អស់លោក ជាទីប្រឹក្សា ជំនួយការ ដើម្បីអនុវត្ត
- ពិនិត្យ និងផ្តល់យោបល់លើរាល់កិច្ចការ សំណុំឯកសារ លិខិត ឬសំណើនានារបស់ទីប្រឹក្សា ជំនួយការ ដែលត្រូវសុំយោបល់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ពិនិត្យ និងវាយតម្លៃលើស្នាដៃការងាររបស់ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការ ជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គ្រប់គ្រងសំណុំឯកសារផ្ទាល់ខ្លួនរបស់ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការ
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៣.-** ឯកឧត្តម លោកជំទាវ អស់លោកជាទីប្រឹក្សា ជំនួយការរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាំងអស់ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០៩-០១២ ប្រក

# ប្រកាស

ស្តីពី

## សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- ប្រកាសលេខ ធ៧.០៧-១៦៣ ប្រក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩

## សម្រេច

**ប្រការ ១ .-**

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណជន ។

**ប្រការ ២ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្នើសុំប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ

ប្រចាំឆ្នាំឱ្យធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ÷

១- ទីស្នាក់ការកណ្តាល : ៥.០០០.០០០ រៀល

២- សាខា : ១.៥០០.០០០ រៀល ក្នុងមួយសាខា

**ប្រការ ៣ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលបើកទីស្នាក់ការកណ្តាល ឬសាខា នៅក្នុងឆ្នាំ ត្រូវបង់សោហ៊ុយ អាជ្ញាប័ណ្ណ ដូចខាងក្រោម ÷

- ក្នុងត្រីមាសទីមួយ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន : ត្រូវបង់មួយត្រីមាស

**ប្រការ ៤ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនប្រាំសែនរៀល (៥០០.០០០រៀល) នៅពេលដាក់ពាក្យសុំអាជ្ញាប័ណ្ណ ។

**ប្រការ ៥ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៦ .-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ខែ មករា ឆ្នាំ២០០៩

ទេសាភិបាល ៖

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.09 – 012 Prokor

**Unofficial Translation**

# PRAKAS
# ON
# LICENSE FEES FOR MICROFINANCE DEPOSIT TAKING INSTITUTIONS

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996, promulgating the Law on the organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008, on the reappointment of His Excellency Chea Chanto as Governor of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Prakas B7.07-163 on the Licensing of Microfinance Deposit Taking Institutions, dated on December 13, 2007;
- Pursuant to the request of the General Directorate;
- Pursuant to the recommendation made by National Bank of Cambodia management during the January 19, 2009, meeting.

## DECIDES

**Article 1**

To set fees for licenses of Microfinance Institutions, takes business to collect deposits from public.

**Article 2**

Microfinance Deposits Taking Institutions shall pay annual license fees to the National Bank of Cambodia as follows:

1- Head office : KHR 5,000,000
2- Branches : KHR 1,500,000 each

**Article 3**

Microfinance Deposit Taking Institutions, where Head Offices or Branches were established during the year, shall pay license fees as follows:

- In the first quarter : license fee in full
- In the second quarter : ¾ of license fee
- In the third quarter : half of license fee
- In the fourth quarter : ¼ of license fee

**Article 4**

Microfinance Deposit Taking Institutions shall pay a fee of KHR500,000 upon submission of the application for a license.

**Article 5**

The General Directorate, the Secretariat General, the Inspection General, the Cashier General, all Departments of the National Bank of Cambodia, all Banks and Financial Institutions, and the Representative Offices of foreign banks under the National Banks of Cambodia's supervisory authority shall strictly implement this Prakas.

**Article 6**

This Prakas shall have effect from the signing date.

Phnom Penh, January 20, 2009

**The Governor**
**signed and sealed**

cc: - The member of the Board of Directors
- The parties concerned as stated in Article 5
- File
- CM "for info."
- Administration
- Department of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...ធ៧.០៩.០១៣...ប្រក...

# ប្រកាស

## ស្តីពី

## ការផ្តល់ឥណទានវិបារូបន៍ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- បានឃើញប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩



Nays

# ស ម្រេ ច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ធនាគារជាតិនៃកម្ពុជា អាចផ្តល់ឥណទានវិបារូបន៍ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន " ដើម្បីដោះស្រាយកង្វះខាតសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ក្រោមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងប្រកាសនេះ ។

**ប្រការ ២.-**

ការរក្សានូវភាពរឹងមាំនៃសាច់ប្រាក់ងាយស្រួល និងសាធនភាពបានជាអចិន្ត្រៃយ៍របស់គ្រឹះស្ថាន គឺជាការទទួលខុសត្រូវជាអាទិភាពរបស់គណៈគ្រប់គ្រងគ្រឹះស្ថាន ។

សាច់ប្រាក់ងាយស្រួលគឺជាលទ្ធភាពរបស់គ្រឹះស្ថានក្នុងការរកមូលនិធិដើម្បីបង្កើនទ្រព្យសកម្ម និងបំពេញបាននូវកាតព្វកិច្ចទូទាត់បំណុលទាន់ពេលវេលា ដោយជៀសវាងនូវការខាតបង់ដែលមិនអាចទទួលយកបាន ។ គ្រឹះស្ថាន នឹងជួបប្រទះវិបត្តិ ប្រសិនបើគ្រឹះស្ថានពុំអាចបំពេញកាតព្វកិច្ចទូទាត់បំណុលទាន់ពេលវេលា ហើយការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលពឹងផ្អែកលើសម្មតិកម្មដែលពុំមានស្ថិរភាពនិងអាចជឿទុកចិត្តបានក្នុងរយៈពេលកន្លងមក ។ ដូច្នេះ គ្រឹះស្ថានត្រូវបង្កើតគោលនយោបាយនិងសម្មតិកម្មប្រុងប្រយ័ត្ន កំណត់ទុកជាមុននូវកម្រិតហានិភ័យសាច់ប្រាក់ងាយស្រួលដែលអាចទទួលយកបាន និងពិចារណាលើការផ្លាស់ប្តូរស្ថានភាពទីផ្សារដែលអាចមានផលអវិជ្ជមានដល់ស្ថានភាពសាច់ប្រាក់ងាយស្រួល ។

ជាងនេះទៅទៀត គ្រឹះស្ថានត្រូវតែព្យាករណ៍ដោយធ្វើសេណារីយ៉ូសាកល្បង ( stress scenarios ) សមហេតុផល ហើយបង្កើតផែនការរកមូលនិធិបន្ទាន់នាពេលខាងមុខ សំដៅទប់ទល់នឹងស្ថានភាពផ្លាស់ប្តូរអវិជ្ជមាននេះ ហើយទប់ស្កាត់ស្ថានភាពមិនអាចទូទាត់សងបំណុលកុំឱ្យកើតមានឡើង ដែលស្ថានភាពបែបនេះអាចនឹងធ្វើឱ្យខូចខាតដល់កិត្តិស័ព្ទរបស់គ្រឹះស្ថានផងដែរ ។

ជាចុងក្រោយ គ្រឹះស្ថានត្រូវចាត់វិធានការសមស្រប ដើម្បីអនុលោមតាមកាតព្វកិច្ចផ្សេងទៀត ដូចជាការរក្សាទុកប្រាក់បម្រុងនៅធនាគារជាតិនៃកម្ពុជា ជាដើម ។

**ប្រការ ៣.-**

រាល់គោលការណ៍គ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការកំណត់នូវកម្រិតហានិភ័យដែលអាចទទួលយកបាន តម្រូវឱ្យរក្សាកម្រិតសាច់ប្រាក់ងាយស្រួលមួយដែលលើសពីតម្រូវការ និងបង្កើតគោលនយោបាយនិងនីតិវិធីត្រឹមត្រូវ សំដៅចាត់វិធានការទាន់ពេលនិងសមស្រប ដូចជាការកាត់បន្ថយឥណទាន ឬការប្រើប្រាស់មូលនិធិដទៃទៀត ដែលវិធានការទាំងនេះ អាចជួយបំពេញកង្វះខាតសាច់ប្រាក់ងាយស្រួលបាន ។

ប៉ុន្តែ ដោយមានការផ្លាស់ប្តូរស្ថានភាពឬនិន្នាការទីផ្សារ ដែលមិនអាចព្យាករណ៍ទុកមុនបានឬមិនធ្លាប់មានពីមុនមក គោលនយោបាយប្រុងប្រយ័ត្ន នីតិវិធី ការរក្សាកម្រិតសាច់ប្រាក់ងាយស្រួលលើសពីតម្រូវការ និងការប្រមើលមើលអំពីការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលទាំងនេះ ក៏នៅតែបង្ហាញនូវភាពមិនគ្រប់គ្រាន់ក្នុងការប្រឈមជាមួយនឹងកង្វះសាច់ប្រាក់ងាយស្រួលតឹងតែងធ្ងន់ធ្ងរ ។

**ប្រការ ៤.-**

ដោយផ្អែកលើហានិភ័យដែលអាចកើតមានខាងលើ ធនាគារជាតិនៃកម្ពុជា អាចផ្តល់ឥណទានវិបារូបនី ចំពោះគ្រឹះស្ថានដែលមានសាធនភាពពេញលេញ ក្នុងគោលបំណងជួយស្តារស្ថានភាពកង្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្នរបស់គ្រឹះស្ថាននោះ ។

## ជំពូក ២

## គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលអាចទទួលបានឥណទានវិបារូបន៍

**ប្រការ ៥.-**

ឥណទានវិបារូបនីត្រូវបានផ្តល់ឱ្យក្នុងកាលៈទេសៈពិសេស ដើម្បីជួយគ្រឹះស្ថានដែលអាចទទួលបានឥណទានវិបារូបនីនេះ ឱ្យរួចផុតពីកង្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន ឬរយៈពេលខ្លី ដូចមានចែងក្នុងប្រការ ៤ ខាងលើ ។

គ្រឹះស្ថាន មិនត្រូវចាត់ទុកឥណទានវិបារូបនីនេះជាការផ្តល់ឥណទានជាលក្ខណៈប្រព័ន្ធឡើយ ហើយជាគោលការណ៍មិនត្រូវពឹងផ្អែកទាំងស្រុងទៅលើឥណទាននេះដើម្បីប្រកាន់យកនីតិវិធី និងគោលនយោបាយប្រុងប្រយ័ត្នធូររលុងដើម្បីគ្រប់គ្រងសាច់ប្រាក់ងាយស្រួលឡើយ ។ ជាងនេះទៅទៀត ឥណទានវិបារូបនីនេះមិនត្រូវបានផ្តល់សម្រាប់ដោះស្រាយស្ថានភាពអសាធនភាព ឬស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយឡើយ ដែលស្ថានភាពទាំងនោះតម្រូវឱ្យដោះស្រាយដោយវិធានការ ត្រួតពិនិត្យប្រុងប្រយ័ត្នដទៃទៀតសមស្របទៅតាមភាពធ្ងន់ធ្ងរនៃបញ្ហាដែលប្រឈម ។

Nay

**ប្រការ ៦.-**

គ្រឹះស្ថានដែលស្នើសុំឥណទានវិបារូបន៍ ត្រូវមានប្រាក់ចំណេញ មានសាធនភាព និងអនុវត្តបានពេញលេញតាមកាតព្វកិច្ចដើមទុនអប្បបរមា និងអនុបាតសាធនភាព ។

ប្រសិនបើធនាគារជាតិនៃកម្ពុជាបានវាយតម្លៃថា គ្រឹះស្ថានពិតជាកំពុងប្រឈមនឹងវិបត្តិធ្ងន់ធ្ងរជាងកង្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន នោះធនាគារជាតិនៃកម្ពុជានឹងមានផែនការដោះស្រាយសមស្រប ។

## ជំពូក ៣
## លក្ខខណ្ឌនៃការស្នើសុំឥណទានវិបារូបន៍

**ប្រការ ៧.-**

គ្រឹះស្ថាន ត្រូវស្នើសុំឥណទានវិបារូបន៍ពីធនាគាជាតិនៃកម្ពុជា បន្ទាប់ពីបានរកឃើញសញ្ញាថា កង្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ននឹងអាចកើតមានឡើង ដោយសារមានការផ្លាស់ប្តូរស្ថានភាពឬនិន្នាការទីផ្សារ ដែលមិនបានដឹងមុន។ គ្រឹះស្ថាន ត្រូវយកចិត្តទុកដាក់អនុវត្តតាមបទប្បញ្ញត្តិស្តីពីប្រាក់បម្រុងកាតព្វកិច្ចអប្បបរមានៅពេលព្យាករណ៍កង្វះសាច់ប្រាក់ងាយស្រួល ហេតុនេះ គ្រឹះស្ថានមិនត្រូវគិតថាការដកប្រាក់បម្រុងកាតព្វកិច្ចមកប្រើប្រាស់ជាវិធានការសមស្រប ដើម្បីដោះស្រាយកង្វះសាច់ប្រាក់ងាយស្រួលនោះឡើយ ។

**ប្រការ ៨.-**

នៅពេលស្នើសុំឥណទានវិបារូបន៍ពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានត្រូវផ្តល់នូវការវិភាគ និងទិន្នន័យជាលាយលក្ខណ៍អក្សរដូចខាងក្រោម :

១. ការព្យាករណ៍សាច់ប្រាក់ងាយស្រួល និងកាលបរិច្ឆេទកង្វះសាច់ប្រាក់ងាយស្រួលដែលនឹងអាចកើតមានឡើង

២. សម្មតិកម្មដែលបានជ្រើសរើសក្នុងការព្យាករណ៍សាច់ប្រាក់ងាយស្រួល រួមទាំងការសាកល្បងសេណារីយ៉ូ (stress scenarios) ផងដែរ

៣. ការវិភាគអំពីការផ្លាស់ប្តូរនិន្នាការ និង/ឬស្ថានភាពទីផ្សារដែលអាចនាំឱ្យមានកង្វះសាច់ប្រាក់ងាយស្រួលដែលអាចដឹងបានជាមុន

៤. ផែនការស្តារស្ថានភាពកង្វះសាច់ប្រាក់ងាយស្រួលប្រកបដោយស្ថិរភាព ដែលនឹងត្រូវបំពេញជាបណ្តោះអាសន្នដោយឥណទានវិបារូបន៍

Nay S

៥. ការប៉ាន់ស្មានដោយប្រុងប្រយ័ត្នលើពេលវេលាចាំបាច់សម្រាប់អនុវត្តផែនការស្តារស្ថានភាព និងទូទាត់សងមកវិញនូវឥណទានវិបារូបន៍

៦. ការព្យាករណ៍អំពីផលប៉ះពាល់ និងបច្ច័យដែលអាចកើតមានឡើងក្នុងការអនុវត្តផែនការស្តារស្ថានភាពទៅលើលទ្ធភាពចំណេញ (តម្លៃនៃមូលនិធិ ប្រភពផ្សេងទៀតនៃមូលនិធិ ការជម្រះទ្រព្យសកម្ម) និងសាធនភាព និង

៧. ការវាយតម្លៃលើស្ថានភាពរួមរបស់គ្រឹះស្ថាន ដើម្បីជាជំនួយដល់ការធ្វើសេចក្តីសម្រេចរបស់ធនាគារជាតិនៃកម្ពុជា និងដើម្បីបង្ហាញថា គ្រឹះស្ថានកំពុងមានសាធនភាពពេញលេញ និងមានចំណេញ។

## ប្រការ ៩.-

សំណុំឯកសារស្នើសុំ ត្រូវផ្អែកលើទិន្នន័យត្រឹមត្រូវ។ ប្រសិនបើ ទិន្នន័យនិងហេតុការណ៍ទាំងឡាយដែលបានរាយការណ៍ បង្ហាញថា មិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ដោយចេតនានិងនាំឱ្យជះឥទ្ធិពលជាវិជ្ជមានលើសេចក្តីសម្រេចចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជា នោះធនាគារជាតិនៃកម្ពុជានឹងដាក់ទណ្ឌកម្មចំពោះគ្រឹះស្ថាន យោងតាមមាត្រា៥២នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

សំណុំឯកសារស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវបញ្ជីនៃវត្ថុធានាមកធនាគារជាតិនៃកម្ពុជា ដើម្បីធានាចំពោះឥណទានវិបារូបន៍នោះ។

## ប្រការ ១០.-

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងអំពីសេចក្តីសម្រេចដល់គ្រឹះស្ថានដែលបានស្នើសុំ ក្នុងរយៈពេល២ (ពីរ) ថ្ងៃធ្វើការ ចាប់ពីថ្ងៃបានទទួលសំណុំឯកសារគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។

សេចក្តីសម្រេចរបស់ធនាគារជាតិនៃកម្ពុជាអាចភ្ជាប់ជាមួយនូវវិធានការនិងលក្ខខណ្ឌមួយចំនួន ដែលអាចតម្រូវឱ្យមានការតាមដានបន្ថែមទៀត ក្នុងគោលបំណងធ្វើឱ្យការវាយតម្លៃស្ថានភាពទូទៅរបស់គ្រឹះស្ថានកាន់តែប្រសើរឡើង ដោយយកចិត្តទុកដាក់លើការត្រួតពិនិត្យដល់ទីកន្លែង និងពិនិត្យកាត់បន្ថយតម្លៃ (Haircut) ឱ្យបានសមស្របតាមវត្ថុធានាដែលដាក់បញ្ចាំ និងការងារផ្សេងទៀតដែលចាំបាច់ក្នុងការសម្រេចឱ្យបានច្បាស់លាស់។

## ប្រការ ១១.-

ឥណទានវិបារូបន៍ អាចត្រូវបានផ្តល់ជាប្រាក់ដុល្លារអាមេរិក ឬជាប្រាក់រៀល ដោយផ្អែកលើកង្វះសាច់ប្រាក់ងាយស្រួល ដែលបានព្យាករណ៍ទុកជាមុនដោយគ្រឹះស្ថានស្នើសុំ។

Nay

ឥណទានវិបារូបន៍ដែលបានស្នើសុំ ត្រូវផ្អែកលើប្រាក់បម្រុងកាតព្វកិច្ចដែលគ្រឹះស្ថានត្រូវប្រតិបត្តិតាម ។ សំណើសុំឥណទានវិបារូបន៍មិនត្រូវលើសពី ៥០% នៃប្រាក់បម្រុងកាតព្វកិច្ច ។

សោហ៊ុយទម្រង់ការ និងអត្រាការប្រាក់លើឥណទានវិបារូបន៍នេះ គឺជាអត្រាការប្រាក់មិនលើកទឹកចិត្ត នឹងត្រូវបានកំណត់តាមការដាក់ស្តែងដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១២.-**

ឥណទានវិបារូបន៍ នឹងត្រូវបានផ្តល់ដល់គ្រឹះស្ថានក្នុងគោលបំណងជួយដោះស្រាយកង្វះសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីដំបូងចាប់ពី១ (មួយ) សប្តាហ៍ ដល់១ (មួយ) ខែ ។

ឥណទានវិបារូបន៍អាចត្រូវបានពន្យារពេលជាថ្មី ដែលមិនអាចលើសពី១ (មួយ) ខែ និងមិនអាចលើសពី២ (ពីរ) ដងឡើយ ។ ក្នុងករណីដែលគ្រឹះស្ថាននៅតែមានសាធនភាព និងស្ថិតក្នុងស្ថានភាពដំណើរការបាន គ្រឹះស្ថានអាចបន្តអនុវត្តផែនការសមស្របដែលបានស្នើឡើង ប៉ុន្តែបើផែនការសកម្មភាពមិនគ្រប់គ្រាន់ ធនាគារជាតិនៃកម្ពុជា នឹងដាក់វិធានការកែតម្រូវបន្ទាន់បន្ថែមទៀត ដែលជាចុងបញ្ចប់ អាចដោះស្រាយបញ្ហាសាច់ប្រាក់ងាយស្រួលប្រកបដោយនិរន្តរភាព ។

បើការអនុវត្តផែនការស្តារស្ថានភាពដែលបានស្នើ ពុំអាចនាំទៅដល់ការដោះស្រាយស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានឱ្យមាននិរន្តរភាពនិងប្រសើរឡើងក្រោយពីការពន្យារពេលឥណទានវិបារូបន៍ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការត្រួតពិនិត្យសមស្របណាមួយ ដើម្បីដោះស្រាយបញ្ហារបស់គ្រឹះស្ថាន និងធ្វើសេចក្តីសម្រេចចិត្ត ។

## ជំពូក ៤

## វត្ថុធានាសមស្រប និងការកាត់បន្ថយតម្លៃ

**ប្រការ ១៣.-**

ក្រៅពីវត្ថុធានាដែលមានចែងក្នុងមាត្រា ៣៦ និង ៣៧ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានអាចស្នើដាក់ឥណទានដែលបានផ្តល់ឱ្យអតិថិជនរបស់ខ្លួន ជាវត្ថុបញ្ចាំក្នុងគោលបំណងធានាលើការសុំខ្ចីឥណទានវិបារូបន៍ ។

ឥណទានដាក់បញ្ចាំបែបនេះត្រូវតែជាឥណទានដំណើរការ (ស្តង់ដារ) នៅក្នុងបញ្ជីរបស់គ្រឹះស្ថាន ។ ឥណទានមិនដំណើរការ (ក្រោមស្តង់ដា សង្ស័យ បាត់បង់) មិនអាចចាត់ទុកជាវត្ថុបញ្ចាំ សម្រាប់ធានាឥណទានវិបារូបន៍ នឹងត្រូវបាន

Nay S

បដិសេធដោយធនាគារជាតិនៃកម្ពុជា។ ឥណទានដែលអាចទទួលយកបានត្រូវឆ្លើយតបតាមរាល់លក្ខខណ្ឌនិងកាតព្វកិច្ច ដែលមានចែងក្នុងបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទានដែលចេញដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថាន ត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា នូវបញ្ជីលំអិតនៃវត្ថុធានា និងឥណទានដែលបានផ្តល់ឱ្យអតិថិជន ដូចជា ប្រាក់ដើម ឈ្មោះអតិថិជន ប្រភេទឥណទាន ចំណាត់ថ្នាក់ឥណទាន រយៈពេលខ្ចី តារាងសងរំលោះ ចំនួនប្រតិបត្តិការ កាលវសាន្ត និងវត្ថុបញ្ចាំសម្រាប់ធានាឥណទាន។

ឥណទាន និងឥណទានផ្សេងទៀតដែលបានផ្តល់ឱ្យសម្ព័ន្ធញាតិមិនត្រូវបានទទួលយក ហើយធនាគារជាតិនៃកម្ពុជា នឹងតម្រូវឱ្យមានវត្ថុបញ្ចាំជំនួសបន្ថែមផ្សេងទៀត។ ធនាគារជាតិនៃកម្ពុជា នឹងបដិសេធវត្ថុធានា ក្នុងករណីដែលមានការសង្ស័យអំពីទំនាក់ទំនងជិតស្និទ្ធជាមួយសម្ព័ន្ធញាតិខាងផ្នែកសេដ្ឋកិច្ច ឬ អាជីវកម្ម។ សេចក្តីសម្រេចបដិសេធរបស់ធនាគារជាតិនៃកម្ពុជាមិនមែនជាកម្មវត្ថុនៃការតវ៉ាឡើយ ។

ឥណទាន និងឥណទានផ្សេងទៀតដែលបានដាក់ជាវត្ថុធានាត្រូវតែបានធ្វើពិពិធកម្ម ដើម្បីជៀសវាងបញ្ហាប្រមូលផ្តុំណាមួយដូចជា ហានិភ័យចំពោះអ្នកខ្ចីតែម្នាក់ ក្រុមអ្នកខ្ចីតែមួយ និងវិស័យសេដ្ឋកិច្ចតែមួយ។ ធនាគារជាតិនៃកម្ពុជា នឹងធានាភាពសមស្របនៃការធ្វើពិពិធកម្មហានិភ័យ ដោយតម្រូវឱ្យមានទ្រព្យសកម្មច្រើនសម្រាប់ដាក់បញ្ចាំ និងពិនិត្យឡើងវិញនូវតម្រូវការនៃពិពិធកម្មនោះ។

គ្រឹះស្ថានមិនត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវឥណទាន ឬឥណទានផ្សេងទៀត ជាវត្ថុបញ្ចាំដែលដល់កាលវសាន្តនៅក្នុងរយៈពេលនៃឥណទានវិបារូបន៍ឡើយ ។

## ប្រការ ១៤.-

វត្ថុធានា ត្រូវមានតម្លៃតាមតម្លៃចុះបញ្ជីនៅកាលបរិច្ឆេទជិតបំផុតទៅនឹងការរៀបចំបញ្ជីវត្ថុធានា ដែលត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា។

## ប្រការ ១៥.-

ធនាគារជាតិនៃកម្ពុជា កាត់បន្ថយ ៤០% នៃតម្លៃវត្ថុបញ្ចាំសរុបដែលដាក់ធានាលើឥណទានវិបារូបន៍ មានន័យថា បើវត្ថុបញ្ចាំមានតម្លៃ ១០០ ឥណទានវិបារូបន៍អាចផ្តល់បានត្រឹមតែ ៦០ ប៉ុណ្ណោះ។

ធនាគារជាតិនៃកម្ពុជា អាចបង្កើនកម្រិតកាត់បន្ថយតម្លៃថែមទៀតទៅតាមទំហំហានិភ័យជាក់ស្តែង បើពិនិត្យឃើញនូវភស្តុតាងថា វត្ថុបញ្ចាំជាឥណទានមិនដំណើរការ ឬ តម្រូវឱ្យចាត់ថ្នាក់ជាឥណទានមិនដំណើរការនៅក្នុងបញ្ជីរបស់គ្រឹះស្ថាន។

## ជំពូក ៥
## ទ្រព្យដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា

**ប្រការ ១៦.-**

ឥណទាន និងទ្រព្យសកម្មសមស្របដទៃទៀតដែលបានដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា ជាវត្ថុធានាលើឥណទានវិបារូបនី ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នៅក្នុងបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថាន ។

ការដាក់វត្ថុបញ្ចាំ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអនុលោមតាមទម្រង់គតិយុត្ត និងបទបញ្ញាជាធរមាន ដើម្បីការពារផលប្រយោជន៍របស់ធនាគារជាតិនៃកម្ពុជា និងដើម្បីទប់ស្កាត់ការប្តឹងទាមទាររួមគ្នា ពីសំណាក់ភាគីឱ្យខ្ចីផ្សេងទៀតដែលមានវត្ថុបញ្ចាំ ។

ធនាគារជាតិនៃកម្ពុជា ជាឥណទាយកមានអាទិភាព ទទួលបានសំណងពេញលេញនៃឥណទានវិបារូបន៍ ការប្រាក់បង្គរ ការផាកពិន័យ និងសោហ៊ុយទម្រង់ការផ្សេងទៀត ។

**ប្រការ ១៧.-**

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិពេញលេញលើវត្ថុដែលបានដាក់បញ្ចាំ និង អាចមានវិធានការត្រួតពិនិត្យនិងប្តឹងទៅតុលាការ បើគ្រឹះស្ថានមានចេតនាលាក់បាំងព័ត៌មានពាក់ព័ន្ធនឹងវត្ថុបញ្ចាំ ដែលអាចរារាំងសិទ្ធិរបស់ធនាគារជាតិនៃកម្ពុជាលើវត្ថុបញ្ចាំនោះ ។

ដើម្បីធានាអាទិភាពជាឥណទាយក ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រឹះស្ថានផ្តល់ឯកសារច្បាប់ដើម រួមមានកិច្ចសន្យា ឯកសារឥណទាន ឯកសារភស្តុតាងផ្សេងៗទៀត ប័ណ្ណកម្មសិទ្ធិ និងវត្ថុផ្សេងទៀតដែលបានដាក់បញ្ចាំធានាឥណទានទាំងនោះ ។

ក្នុងករណីដែលព្រឹត្តិការណ៍ណាមួយដូចមានចែងនៅក្នុងប្រការ ២១ ចំណុច ក និង ខ កើតឡើង គ្រឹះស្ថានត្រូវផ្តល់វត្ថុធានាជំនួស សមស្រប និងឯកសារពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងកថាខ័ណ្ឌ២នៃប្រការនេះ បន្ទាប់ពីមានការព្រមព្រៀងជាមុនពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា អាចប្រគល់ឯកសារច្បាប់ដើមទាក់ទងទៅនឹងឥណទាន និងឥណទានផ្សេងទៀត ដែលត្រូវបានដកចេញពីសំណុំវត្ថុធានា ។

**ប្រការ ១៨.-**

គ្រឹះស្ថាន ត្រូវបង្ហាញវត្ថុធានាដែលដាក់បញ្ចាំនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ក្នុងទម្រង់ជាកំណត់

Nay S

សំគាល់ ដោយសង្ខេបនូវចំនួនប្រាក់ និងលក្ខណៈចំបងៗនៃទ្រព្យសកម្ម ដែលបានដាក់បញ្ចាំនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលឥណទានវិបារូបន៍នៅមានសុពលភាពនាការិយបរិច្ឆេទនៃរបាយការណ៍ ។

## ជំពូក ៦

## ការពិនិត្យគុណភាពវត្ថុបញ្ចាំឡើងវិញ

### ប្រការ ១៩.-

ធនាគារជាតិនៃកម្ពុជា ពិនិត្យវត្ថុបញ្ចាំឡើងវិញតាមវិធីសាស្ត្រសមស្រប មុននឹងសម្រេចជាចុងក្រោយ លើលក្ខខណ្ឌនៃការស្នើសុំឥណទានវិបារូបន៍ ។

ការពិនិត្យវត្ថុបញ្ចាំឡើងវិញទាំងនេះ ត្រូវធ្វើឡើងតាមរយៈការត្រួតពិនិត្យដល់ទីកន្លែង ក្នុងគោលបំណងផ្ទៀងផ្ទាត់នូវចំណុចមួយចំនួនដូចខាងក្រោម:

- ភាពត្រឹមត្រូវនៃកម្មសិទ្ធិវត្ថុដាក់បញ្ចាំដែលបានស្នើសុំ
- លក្ខណៈរបស់វត្ថុធានារួមមាន អត្ថិភាព និងសុពលភាពនៃវត្ថុធានា ប័ណ្ណកម្មសិទ្ធិ និងមធ្យោបាយកាត់បន្ថយហានិភ័យឥណទានផ្សេងទៀត ដើម្បីធានាឥណទានដែលបានស្នើដាក់បញ្ចាំ
- ការខកខានមិនបានធ្វើចំណាត់ថ្នាក់នៅក្នុងបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថាននោះ ក៏ដូចជាការកត់ត្រាចំណាត់ថ្នាក់ឥណទានដំណើរការ និងឥណទានមិនដំណើរការក្នុងគ្រាកន្លងមក និង
- លក្ខខណ្ឌទាំងឡាយ ដែលក្នុងនោះ ឥណទាន និងទ្រព្យសកម្មដែលត្រូវបានស្នើដាក់ជាវត្ថុបញ្ចាំសម្រាប់ធានា ដើម្បីការពារនូវផលប្រយោជន៍របស់ធនាគារជាតិនៃកម្ពុជា ។

### ប្រការ ២០.-

ចំពោះវត្ថុធានាដែលត្រូវបដិសេធដោយសារបញ្ហាមិនដំណើរការ ឬការព្រួយបារម្ភផ្សេងៗទៀត ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានធ្វើចំណាត់ថ្នាក់ឡើងវិញជាបន្ទាន់លើលក្ខខណ្ឌចុះកិច្ចបញ្ជិកាគណនេយ្យ និងការធ្វើសវិធានធនហានិភ័យស្របទៅនឹងតម្រូវការ ដូចមានចែងក្នុងបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន ។

## ជំពូក ៧

## កាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា

### ប្រការ ២១.-

គ្រឹះស្ថាន មានកាតព្វកិច្ចរាយការណ៍មកធនាគារជាតិនៃកម្ពុជា បន្ទាប់ពីបានទទួលឥណទានវិបារូបន៍ រហូតដល់ធនាគារជាតិនៃកម្ពុជាលែងមានតម្រូវការអំពីរបាយការណ៍ទាំងនោះ ។

Nay

កាតព្វកិច្ចរាយការណ៍នេះ នឹងត្រូវផ្អែកលើកាលៈទេសៈមិនល្អដែលជះឥទ្ធិពលលើស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន និងស្របតាមទម្រង់ហានិភ័យជារួម ដែលវាយតម្លៃដោយធនាគារជាតិនៃកម្ពុជា លើស្ថានភាពទូទៅរបស់គ្រឹះស្ថាននោះ ។ ភាពញឹកញាប់នៃរបាយការណ៍ ត្រូវតែសមស្របទៅតាមការវាយតម្លៃហានិភ័យ ។

គ្រឹះស្ថានដែលទទួលបានឥណទានវិបារូបនី ត្រូវមានកាតព្វកិច្ចរាយការណ៍ជាអប្បបរមាមកធនាគារជាតិនៃកម្ពុជា ដូចតទៅ :

ក- រាល់ការសម្រេចធ្វើចំណាត់ថ្នាក់លើវត្ថុដែលដាក់បញ្ចាំ ក្នុងអំឡុងពេលសុពលភាពនៃឥណទានវិបារូបនីនិងរាល់សំណើពាក់ព័ន្ធនឹងការដាក់វត្ថុបញ្ចាំថ្មីជំនួសវត្ថុបញ្ចាំដែលត្រូវបានធ្វើចំណាត់ថ្នាក់ ។

ខ- រាល់ព្រឹត្តិការណ៍ដែលកើតមានចំពោះវត្ថុបញ្ចាំនៅធនាគារជាតិនៃកម្ពុជា ដោយមិនកំណត់ត្រឹមតែការមិនសងប្រាក់ ឬការទូទាត់សងមុនកាលកំណត់

គ- ការវិវឌ្ឍនៃការអនុវត្តផែនការស្តារស្ថានភាព និងផលប៉ះពាល់លើស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន

ឃ- ការលំបាកដែលកើតមានឡើងដោយមិនបានដឹងមុនក្នុងការអនុវត្តផែនការស្តារស្ថានភាព និងបញ្ហាប្រឈមផ្សេងៗទៀត ដើម្បីស្តារសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានឱ្យស្ថិតក្នុងកម្រិតគ្រប់គ្រាន់ ។

នៅពេលកាលៈទេសៈតម្រូវ ដោយសារកង្វល់អំពីកង្វះសាច់ប្រាក់ងាយស្រួលធ្ងន់ធ្ងរ និងការធ្លាក់ចុះកាន់តែធ្ងន់ធ្ងរនូវស្ថានភាពរបស់គ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជា នឹងតម្រូវឱ្យមានរបាយការណ៍ប្រចាំថ្ងៃ ស្តីពីលំហូរចូល និងចេញ ក៏ដូចជារបាយការណ៍ស្តីពីការព្យាករណ៍តំលាតសាច់ប្រាក់ងាយស្រួលនៅថ្ងៃបន្ទាប់មកទៀត ។

**ប្រការ ២២.-**

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់នៅពេលដែលមានការពន្យារពេលឥណទានវិបារូបនី ហើយអាចឈានទៅដល់ការត្រួតពិនិត្យដល់ទីកន្លែង ក្នុងគោលបំណងតាមដានទាំងស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាព ។

## ជំពូក ៨

## អវសានបញ្ញត្តិ

**ប្រការ ២៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទ

ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២៤.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ២៣ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7-09-013 Prokor.

**Unofficial translation**

# Prakas on

